**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ០១៦/១៨ **ក.ប**/ស.ជ.ណ.ម.ហ

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីជូនដំណឹងលេខ ២៧២ កប/ស.ជ.ណ.ម.ហ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ដោយកំណត់យកដំណាច់ខែមីនា ឆ្នាំ២០១៨ ជាឱសានវាទក្នុងការពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេស។

ចំពោះករណីនេះ ក្រសួងបានពិនិត្យឃើញថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេស មួយចំនួន នៅមិនទាន់បានស្នើសុំពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេសតាមរយៈគេហទំព័រ www.fwcms.mlvt.gov.khនៅឡើយ ដើម្បីបញ្ចៀសការផាកពិន័យតាមអត្រាប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ៤០ ០០០៛(សែសិបពាន់រៀល) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាប ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសដែលប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា ក្រសួងបានពន្យារពេល សម្រាប់ការស្នើសុំពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេស រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាប ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសដែលប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រញាប់ស្នើសុំពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេសតាមរយៈគេហទំព័រ www.fwcms.mlvt.gov.kh ឲ្យបានមុនថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ជាកំហិត។ ចំពោះការខកខានមិនបានពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេសមុនកាលកំណត់ ក្រសួងនឹងចាត់វិធានការផាកពិន័យតាមទោសប្បញ្ញត្តិក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះដោយប្រសិទ្ធភាព។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក"ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩